ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានព័ត៌មានវិទ្យា ក.ស.ហ.វ
មកដល់ថ្ងៃទី...............ម៉ោង...........
អ្នកទទួល...............ហត្ថលេខា...........
អ្នកប្រគល់ឲ្យ...............ហត្ថលេខា...........

* MINISTRY OF ECONOMY AND FINANCE *

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...............សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែឧសភា ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការកែសម្រួល និងបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤៤-១៥០ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបំបែកសង្កាត់ និងបង្កើតសង្កាត់ក្នុងរាជធានីភ្នំពេញ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៥២-១៥៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតឃុំក្ដុលសែនជ័យ ស្រុកទឹកផុស ខេត្តក្រចេះ និងឃុំគ្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ
- បានឃើញអនុក្រឹត្យលេខ ១៦៤-១៦៥ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតឃុំតានៃ ស្រុកព្រៃនប់ និងសង្កាត់កោះរ៉ុងសន្លឹម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងសៀមរាប និងស្រុកប្រាសាទបាគង ដោយកាត់យកសង្កាត់អំពិលនៃក្រុងសៀមរាប ទៅឱ្យស្រុកប្រាសាទបាគង នៃខេត្តសៀមរាប
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

ត្រូវបានកែសម្រួល និងបំពេញបន្ថែមលេខកូដឃុំ សង្កាត់របស់ចំណាត់ភូមិសាស្ត្រនៃមាតិកាថវិកា នៃប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា ដូចខាងក្រោម÷

| លេខកូដ | ឈ្មោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ |
|---|---|
| 04 | **ខេត្តកំពង់ឆ្នាំង** |
| 0408 | **ស្រុកទឹកផុស** |
| 040809 | ឃុំក្ដុលសែនជ័យ |
| 10 | **ខេត្តក្រចេះ** |
| 1005 | **ស្រុកស្នួល** |
| 100506 | ឃុំគ្រញូងសែនជ័យ |
| 12 | **រាជធានីភ្នំពេញ** |
| 1206 | **ខណ្ឌមានជ័យ** |
| 120608 | សង្កាត់ស្ទឹងមានជ័យទី១ |
| 120609 | សង្កាត់ស្ទឹងមានជ័យទី២ |
| 120610 | សង្កាត់ស្ទឹងមានជ័យទី៣ |
| 120611 | សង្កាត់បឹងទំពន់ទី១ |

| | |
|---|---|
| 120612 | សង្កាត់បឹងទំពន់ទី២ |
| 1207 | **ខណ្ឌឫស្សីកែវ** |
| 120713 | សង្កាត់ទួលសង្កែទី១ |
| 120714 | សង្កាត់ទួលសង្កែទី២ |
| 1208 | **ខណ្ឌសែនសុខ** |
| 120808 | សង្កាត់អូរបែកក្អម |
| 120809 | សង្កាត់គោកឃ្លាង |
| 1209 | **ខណ្ឌពោធិ៍សែនជ័យ** |
| 120914 | សង្កាត់ចោមចៅទី១ |
| 120915 | សង្កាត់ចោមចៅទី២ |
| 120916 | សង្កាត់ចោមចៅទី៣ |
| 120917 | សង្កាត់កាកាបទី១ |
| 120918 | សង្កាត់កាកាបទី២ |
| 17 | **ខេត្តសៀមរាប** |
| 1709 | **ស្រុកប្រាសាទបាគង** |
| 170910 | ឃុំអំពិល |
| 18 | **ខេត្តព្រះសីហនុ** |
| 1801 | **ក្រុងព្រះសីហនុ** |
| 180106 | សង្កាត់កោះរ៉ុងសន្លឹម |
| 1802 | **ស្រុកព្រៃនប់** |
| 180215 | ឃុំតានៃ |

**ប្រការ២._**

ត្រូវបានលុបលេខកូដឃុំ សង្កាត់របស់ចំណាត់ភូមិសាស្ត្រនៃមាតិកាថវិកា នៃប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា ដូចខាងក្រោម÷

| លេខកូដ | ឈ្មោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ |
|---|---|
| 12 | **រាជធានីភ្នំពេញ** |
| 1206 | **ខណ្ឌមានជ័យ** |
| 120601 | សង្កាត់ស្ទឹងមានជ័យ |
| 120602 | សង្កាត់បឹងទំពន់ |
| 1207 | **ខណ្ឌឫស្សីកែវ** |
| 120702 | សង្កាត់ទួលសង្កែ |



4 ✓

| | |
|---|---|
| 1209 | ខណ្ឌពោធិ៍សែនជ័យ |
| 120904 | សង្កាត់ចោមចៅ |
| 120905 | សង្កាត់កាកាប |
| 17 | **ខេត្តសៀមរាប** |
| 1710 | **ក្រុងសៀមរាប** |
| 171011 | សង្កាត់អំពិល |

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤._**

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- លេខាធិការដ្ឋាន គ.ជ.អ.ប

  *"ដើម្បីជូនជ្រាប"*
- អគ្គលេខាធិការដ្ឋាន គ.ស.ហ.វ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត

  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ